CHAIN
គម្រោង បន្លែ ផ្លែឈើ កម្ពុជា

# សៀវភៅណែនាំស្តីពី
# ការដាំបន្លែក្នុងផ្ទះសំណាញ់

**PLASTIC OR NET HOUSE VEGETABLE GROWING MANUAL**






គម្រោង

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**Swiss Agency for Development and Cooperation SDC**

អនុវត្តដោយ

SNV

swisscontact

# មាតិកា

១. សេចក្តីផ្តើម Introduction ........................................................................ 1

២. គោលបំណង Purpose ........................................................................ 1

៣. ការតម្លើងផ្ទះសំណាញ់ How to set up ........................................................ 2

៤. ការជ្រើសរើសពូជសម្រាប់ធ្វើការដាំដុះ Variety Selection................................ 5

៥. ការបង្កើតផ្លែ Fruit Initial........................................................................ 5

៦. ការរៀបចំដី Land Preparation.............................................................. 6

៧. ការស្រោចស្រព Watering........................................................................ 7

៨. ការគ្រប់គ្រងកត្តាចង្រៃ Pest Management.................................................. 7

៩. ព័ត៌មានបន្ថែម Additional Information ...................................................11

## ១. សេចក្តីផ្តើម Introduction៖

ផ្ទះសំណាញ់/ប្លាស្ទិកបាននឹងកំពុងអនុវត្តជាទូទៅក្នុងពិភពលោកលើវិស័យផលិតកម្មដំណាំបន្លែ ដើម្បីការពារឥទ្ធិពលកាំរស្មីពន្លឺព្រះអាទិត្យ បម្រែបម្រួលអាកាសធាតុ(ក្តៅពេក ត្រជាក់ពេក) ខ្យល់ តំណក់ទឹកភ្លៀង សត្វល្អិត និងភ្នាក់ងារចម្លងជម្ងឺតាមបរិយាកាស។

ឈេន/CHAIN ជាកម្រោងបន្លែ ផ្លែឈើកម្ពុជារបស់ស្វីស(SDC)បាននឹងកំពុងអនុវត្តន៍នៅតាមបណ្តាខេត្តគោលដៅមួយចំនួនដូចជា ខេត្តក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ ទទួលបានលទ្ធផលប្រសើរជាងពីមុនដូចជាការបង្កើនវដ្តនៃការដាំដុះ ការការពារពីពពួកកត្តាចង្រៃ ការកើនឡើងនូវទិន្នផលមានគុណភាព និងសុត្ថិភាពផលិតផល។

ផ្អែកលើលទ្ធផល និងជាបទពិសោធន៍ល្អប្រសើរនេះ គម្រោងឈេន/CHAIN នឹងបន្តការគាំទ្រតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីស្ថាប័នដៃគូ សហគមន៍កសិករដើម្បីផ្តល់បច្ចេកទៅដល់ក្រុមដាំបន្លែ និងភ្ជាប់ពួកគាត់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀតឲ្យសម្រេចបាននូវសមិទ្ធិផលខ្ពស់។

## ២. គោលបំណង Purpose៖

សៀវភៅណែនាំពីការអនុវត្តជាក់ស្តែងអំពីការដាំបន្លែនៅក្នុងផ្ទះសំណាញ់/ផ្លិកមានដូចជា៖

- បង្កើនជំនាញដល់មន្ត្រីបច្ចេកទេស និងកសិករអំពីវិធីដាំដុះ និង ការគ្រប់គ្រងដំណាំបន្លែ ក្នុងផ្ទះសំណាញ់




- បង្កើនការគ្រប់គ្រងហានិភ័យ និងភាពធន់ជាមួយ បម្រែបម្រួលអាកាសធាតុ





- បង្កើនការគ្រប់គ្រង ហានិភ័យពីសត្វល្អិត ជម្ងឺ ស្មៅ និងកត្តាចង្រៃផ្សេងៗ


